**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៤២ ស.ស.រ**

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដំណើរការអនុវត្តគម្រោងផ្លូវនាវាចរណ៍ "ព្រែកជីកហ្វូណនតេជោ"

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដំណើរការអនុវត្តគម្រោងផ្លូវនាវាចរណ៍ "ព្រែកជីកហ្វូណនតេជោ" ដែលមានសមាភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្ដម **ស៊ុន ចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | ប្រធាន |
| ២- ឯកឧត្ដម **សុខ ចិន្ដាសោភា** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣- ឯកឧត្ដម **វង្សី វិស្សុត** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- ឯកឧត្ដមកិត្តិបណ្ឌិត **លឹម គានហោ** | រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ៥- ឯកឧត្ដម **អៀង ម៉េងស៊ុន** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិកអចិន្ត្រៃយ៍ |
| ៦- ឯកឧត្ដម **សៀង ឈុនទ្រី** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | | |
|---|---|---|
| ៧- ឯកឧត្តម **ស្រ៊ុន ធីរិទ្ធ** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨- ឯកឧត្តម **ផាន់ ចាន់ធុល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩- ឯកឧត្តម **ផាន់ ផល្លា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១០- ឯកឧត្តម **រស់ សីលវ៉ា** | សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ១១-ឯកឧត្តមបណ្ឌិត **សូស គង់** | រដ្ឋលេខាធិការប្រចាំការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២-ឯកឧត្តម **ទិន ពន្លក** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៣-ឯកឧត្តម **នី ផល្លី** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៤- ឯកឧត្តម **ហ៊ី បាទី** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា ប្រធានអគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ | សមាជិក |
| ១៥- ឯកឧត្តម **គង់ វិមាន** | អនុរដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៦- ឯកឧត្តម **ចាន់ តារា** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៧-ឯកឧត្តម **ស៊ឹម ធីរៈ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៨- ឯកឧត្តម **ឌុច ទនធីតូ** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៩- ឯកឧត្តម **ឃុន សាឡឿន** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២០- ឯកឧត្តម **អ៊ឹម សិទ្ធីរ៉ា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារ គម្រោងអភិវឌ្ឍន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ២១- ឯកឧត្តម **តែ ណារុធ** | អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | សមាជិក |
| ២២- ឯកឧត្តម **ម៉ក់ ស៊ីដេត** | អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធានលេខាធិការដ្ឋាន |
| ២៣-ឯកឧត្តម **ឱម ម៉ាក់ឆារិទ្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ២៤- ឯកឧត្តម **កែន រដ្ឋា** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២៥- ឯកឧត្តម **ហេង រត្នពិសិដ្ឋ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២៦- ឯកឧត្តម **ហ៊ាង ឌុស្តា** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |

https://t.me/oa_channel

| | | |
|---|---|---|
| ២៧-ឯកឧត្តម **ឈៀង ពេជ្រ** | អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារកម្ម ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២៨-ឯកឧត្តម **ម៉ៅ ហាក់** | អនុប្រធានអាជ្ញាធរទន្លេសាប | សមាជិក |
| ២៩-ឯកឧត្តម **សោម ពិសិដ្ឋ** | អភិបាលខេត្តកែប | សមាជិក |
| ៣០-ឯកឧត្តម **ហាក់ សុខមករា** | អភិបាលរងខេត្តកណ្តាល | សមាជិក |
| ៣១-ឯកឧត្តម **ថាន់ ថារិទ្ធ** | អភិបាលរងខេត្តកំពត | សមាជិក |
| ៣២-លោក **គង់ ស៊ីថា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានធនធានរ៉ែ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៣៣-លោក **ហេង សុធី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៣៤-លោក **ខាន់ សុខា** | អភិបាលរងខេត្តតាកែវ | សមាជិក |
| ៣៥-លោក **រស់ សោភ័ណ្ឌា** | ប្រធាននាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងសំណង់កំពង់ផែ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក។ |

**ប្រការ២ .–**

គណៈកម្មការអន្តរក្រសួងនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងផ្តល់យោបល់អំពីនីតិវិធី ក្របខណ្ឌគតិយុត្ត និងវាយតម្លៃប្រសិទ្ធភាពសេដ្ឋកិច្ច និងស្នើទម្រង់នៃការវិនិយោគលើគម្រោងផ្លូវនាវាចរណ៍ "ព្រែកជីកហ្វូណនតេជោ" ដែលតភ្ជាប់ពីព្រែកតាកែវនៃដៃទន្លេមេគង្គទៅសមុទ្រខេត្តកែប

- ជំរុញការរៀបចំគម្រោងវិនិយោគនេះឱ្យបានច្បាស់លាស់ និងស៊ីជម្រៅលើគ្រប់ទិដ្ឋភាព និងស្វែងរកដៃគូវិនិយោគ ដើម្បីអនុវត្តគម្រោងផ្លូវនាវាចរណ៍ "ព្រែកជីកហ្វូណនតេជោ" ឱ្យមានគុណភាព និងប្រសិទ្ធភាព ព្រមទាំងពិនិត្យ វាយតម្លៃ និងចរចាលើកិច្ចព្រមព្រៀងវិនិយោគលើគម្រោងនេះ

- ជំរុញដំណើរការអនុវត្តគម្រោងផ្លូវនាវាចរណ៍ "ព្រែកជីកហ្វូណនតេជោ" ឱ្យបានសម្រេចជាស្ថាពរ ដើម្បីរួមចំណែកពន្លឿនការអភិវឌ្ឍវិស័យដឹកជញ្ជូនតាមផ្លូវទឹក និងផ្លូវសមុទ្ររបស់កម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព ធ្វើឱ្យថ្លៃដឹកជញ្ជូនចុះទាប និងជានាទីភាពនៃកំណើនសេដ្ឋកិច្ចជាតិ

- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៣ .–**

អនុប្រធាន និងសមាជិកគណៈកម្មការអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ករណីមានធុរៈ ប្រធានត្រូវប្រគល់សិទ្ធិជូនអនុប្រធាន ០១រូប ដឹកនាំប្រជុំជំនួស។ គណៈកម្មការអន្តរក្រសួងនេះអាចអញ្ជើញតំណាងពីក្រសួង-ស្ថាប័នពាក់ព័ន្ធនានា និងអ្នកជំនាញដទៃទៀត ឱ្យចូលរួមដើម្បីពិនិត្យ និងផ្តល់យោបល់ក្នុងករណីចាំបាច់។

**ប្រការ៤ .-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួនតាមការចាំបាច់។

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតលេខាធិការដ្ឋានបច្ចេកទេសមួយ ដើម្បីជួយកិច្ចការរដ្ឋបាល បច្ចេកទេស ផែនការ ហិរញ្ញវត្ថុ និងការងារផ្សេងទៀត។

**ប្រការ៥ .-**

គណៈកម្មការអន្តរក្រសួងនេះ ប្រើប្រាស់ត្រារបស់ក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន។

**ប្រការ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៤រោច ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



https://t.me/oa_channel